**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅទីស្តីការក្រសួង ដោយបានពិនិត្យពិភាក្សាអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពទាំង ៥ ដើម្បីកំណត់ទិសដៅអាទិភាពការងារបន្តសម្រាប់ឆ្នាំ២០២៣។ ឯកឧត្តមរដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងក្រសួងស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ និយោជក និងបងប្អូនកម្មករនិយោជិត ដែលបានរួមគ្នាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការសម្រេចបាននូវលទ្ធផលជោគជ័យគួរជាទីមោទនៈ ដូចខាងក្រោម៖

## I- លទ្ធផលការងារឆ្នាំ២០២២

### ១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- បើទោះជាស្ថានភាពជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់សេដ្ឋកិច្ច-សង្គមយ៉ាងណា ក៏ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវបានដំឡើងពី ១៩៤ដុល្លារអាម៉េរិក/ខែ ក្នុងឆ្នាំ២០២២ និងបានកើនដល់ ២០០ដុល្លារអាម៉េរិក/ខែ សម្រាប់ឆ្នាំ២០២៣ បើបូករួមប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ឈ្នួល ចាប់ពី ២១៧ដុល្លារអាម៉េរិក ដល់ ២២៨ដុល្លារអាម៉េរិក/ខែ។
- បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ដោយបានបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ ដែលព្យួរកិច្ចសន្យាការងារដោយសារជំងឺកូវីដ-១៩ ដែលគិតត្រឹមឆ្នាំ២០២២ នេះ សរុបចំនួន ៣៥៤ ២៧៦នាក់ ស្មើនឹងថវិកាប្រមាណ ១៣៤,០៧ប៊ីលានរៀល ព្រមទាំងបានផ្តល់វគ្គបណ្តុះបណ្តាលជំនាញទន់ ដល់កម្មករនិយោជិតប្រមាណ ៦៨ ០០០នាក់។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៩

- បានពង្រឹងការអប់រំផ្សព្វផ្សាយការយល់ដឹងអំពីផលវិបាក ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងវិធានការនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញដល់ម្ចាស់រោងចក្រ សហគ្រាស និងបងប្អូនកម្មករនិយោជិត ដើម្បីចូលរួមអនុវត្តសំដៅធានាបាននូវនិរន្តរភាពអាជីវកម្ម/ផលិតកម្ម និងជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិត។
- បានបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារ ដើម្បីទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ចំនួន ៣វគ្គ សរុបចំនួន ៥២៥នាក់។
- បានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមរយៈការចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចការងារនៅតាមរោងចក្រ សហគ្រាស ចំនួន ៧ ២៣៧លើក ដែលមាន អធិការកិច្ចការងារសាមញ្ញចំនួន ៦ ៦០១លើក ក្នុងនោះរបបស្វ័យប្រកាសអធិការកិច្ចការងារចំនួន ៣ ២១២ សហគ្រាស, អធិការកិច្ចតាមដានការដាក់កំហិតចំនួន ១៧៥សហគ្រាស និងអធិការកិច្ចការងារពិសេស ៤៦១សហគ្រាស និងបានដាក់កំហិតចំនួន ២៩៣សហគ្រាស និងបានផាកពិន័យចំនួន ១៦សហគ្រាស។
- បានដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនៃអធិការកិច្ចការងារ។ ជាក់ស្តែង រោងចក្រ សហគ្រាស បានចុះបញ្ជិកាសេដ្ឋកិច្ចក្នុងប្រព័ន្ធចំនួន ៣ ៧៤៨ បានបើកដំណើរការថ្មី ដែលផ្តល់ការងារដល់កម្មករនិយោជិត សរុបប្រមាណជិត ១៥ម៉ឺននាក់ បន្ថែម។
- បានផ្តល់សេវាពិនិត្យកាយសម្បទាជូនដល់កម្មករនិយោជិតខ្មែរ-បរទេស សរុបចំនួន ៨២១ ០០៣នាក់។
- បានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ហើយបានអនុវត្តកិច្ចអន្តរាគមន៍ស្នូលដកហូត និងទប់ស្កាត់ពលកម្មកុមារចំនួន ៤០០នាក់ (ស្រី ១៩១នាក់)។
- បានលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដែលឆ្លុះបញ្ចាំងតាមរយៈ កំណើនជាបន្តបន្ទាប់នៃការចុះបញ្ជីរបស់អង្គការវិជ្ជាជីវៈ ដោយបានចុះបញ្ជីសហព័ន្ធសហជីពចំនួន ១៥, សហជីពមូលដ្ឋានចំនួន ២៥២ និងសមាគមនិយោជកចំនួន ១ បើគិតត្រឹមឆ្នាំ២០២២ នេះ មានអង្គការវិជ្ជាជីវៈសរុបចំនួន ៦ ០១៤ ក្នុងនោះសហជីពមូលដ្ឋានចំនួន ៥ ៦៩៤, សហព័ន្ធសហជីពចំនួន ២៦៧, សហភាពសហជីពចំនួន ៤០ និងសមាគមនិយោជកចំនួន ១៣។
- បានផ្សះផ្សាវិវាទការងារសរុបចំនួន ៩០៦ករណី ដោយទទួលបានលទ្ធផលសះជាចំនួន ៥៤២ករណី, មិនសះជាចំនួន ២៩៥ករណី និងមោឃៈចំនួន ៦៩ករណី ក្នុងនោះ វិវាទការងាររួមចំនួន ២២៥ករណី និងបានបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៥៣ករណី ក្នុងនោះ បានចេញសេចក្តីបង្គាប់ចំនួន ៤១ករណី សះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៤ករណី និងសះជាដោយភាគីទាំងពីរចំនួន ៨ករណី។ តាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ បានធ្វើឱ្យអត្រាដោះស្រាយសះជាវិវាទការងាររួម ទាំងកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាល មានអត្រាខ្ពស់ប្រមាណ ៩០,៦៤% ដែលឆ្លុះបញ្ចាំងពីភាពល្អប្រសើរនៃយន្តការផ្សះផ្សាវិវាទ និងសមត្ថភាពរបស់មន្ត្រីផ្សះផ្សា។

- បានអន្តរាគមន៍ដោះស្រាយបញ្ហាកូដកម្មសរុបចំនួន ៦៨ករណី ក្នុងនោះ ៩៥,៥៩% ត្រូវបានដោះស្រាយសះជា និងបានធ្វើអន្តរាគមន៍ដោះស្រាយបាតុកម្មចំនួន ៥ករណី ដោយបានដោះស្រាយសះជា ១០០%។
- បានដោះស្រាយករណីរោងចក្របិទទ្វារដោយវិបត្តិផ្សេងៗ សរុបចំនួន ២១ករណី មានកម្មករនិយោជិតសរុបចំនួន ៨ ៤៥៤នាក់ ក្នុងនោះ រាជរដ្ឋាភិបាលបានដោះស្រាយ បើកប្រាក់បុរេប្រទានចំនួន ៦ករណី មានកម្មករនិយោជិត ចំនួន ១ ៩៩៧នាក់ មានទឹកប្រាក់ សរុបចំនួន ២ ០១៨ ០០០ដុល្លារអាម៉េរិក។

**២- ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- បានបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥, ផែនការមេសម្រាប់អភិវឌ្ឍន៍គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេល ៥ឆ្នាំ (២០២១-២០២៥) និងផែនការសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ និងបានរៀបចំផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជាឆ្នាំ២០២២-២០៣៥។
- បានបង្កើនថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ជាបន្តបន្ទាប់ក្នុងការបន្តធ្វើទំនើបកម្មគ្រឹះស្ថាន TVET តាមរយៈការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមាន អគារសិក្សា, រោងជាង/បន្ទប់ពិសោធន៍, អន្តេវាសិកដ្ឋាន, មជ្ឈមណ្ឌលធ្វើតេស្តវាយតម្លៃសមត្ថភាព, មជ្ឈមណ្ឌលឧត្តមភាព, មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍ និងនវានុវត្ត TVET និងបំពាក់ឧបករណ៍បរិក្ខារសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល។
- បានបន្តជំរុញការផ្សព្វផ្សាយពីវិស័យ TVET ទាំងផ្ទាល់ និងតាមឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធនានា តាមរយៈការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET DAY) លើកទី៥ ក្រោមប្រធានបទ "**TVET បង្កើនផលិតភាពការងារ និងភាពប្រកួតប្រជែងខ្ពស់**" នៅគ្រប់រាជធានី ខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន ៤២ ៦៩២នាក់ (ស្រី ២១ ៤៥៨នាក់), ចុះតម្រង់ទិសវិជ្ជាជីវៈ និងផ្សព្វផ្សាយតាមសហគមន៍សរុបចំនួន ១២៧ ៥៨០នាក់ (ស្រី ៦៣ ៣១៨នាក់), រៀបចំការប្រកួតជំនាញជាតិលើកទី៨ មានបេក្ខជនចូលរួមចំនួន ៦១នាក់ (ស្រី ៧នាក់) បេក្ខជនទទួលបានជ័យលាភីលើមេដាយមាស មេដាយប្រាក់ មេដាយសំរិទ្ធ និងវិញ្ញាបនបត្រនិទ្ទេសល្អប្រសើរចំនួន ៥០នាក់ (ស្រី ៥នាក់) និងរៀបចំយុទ្ធនាការស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបៃតង (Green TVET)។
- បានបន្តអភិវឌ្ឍសមត្ថភាពគ្រូបច្ចេកទេសទាំងគរុកោសល្យបង្រៀនផ្អែកលើសមត្ថភាព និងជំនាញបច្ចេកទេសថ្មីៗស្របតាមទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស ចំនួន ១៨៣នាក់ (ស្រី ១៥នាក់) និងបានចុះធ្វើអធិការកិច្ចគ្រូបច្ចេកទេសជាប្រចាំ។
- បានបន្តអភិវឌ្ឍ និងអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ១, ២, ៣, ៤ និងកម្រិត ៥ សម្រាប់វិស័យ សំណង់, មេកានិក, អគ្គិសនី/អេឡិចត្រូនិក, កម្មន្តសាល, បរិក្ខារត្រជាក់ និងកម្តៅ និងធុរកិច្ច/ព័ត៌មានវិទ្យា។
- បានបន្តរៀបចំវគ្គបណ្តុះបណ្តាលពិសេសលើកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1) ពិសេស ជូនដល់កម្មករនិយោជិត និងយុវជនដែលរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ-១៩ មានរយៈពេល ៤ខែ មានសិក្ខាកាម សរុបចំនួន ៧ ៥០០នាក់ (ស្រី ៣ ០៥២នាក់) ដោយសិក្ខាកាមមកពីគ្រួសារក្រ១ ក្រ២ ក្នុងម្នាក់ទទួលបានប្រាក់ឧបត្ថម្ភចំនួន ២០ម៉ឺនរៀល/១ខែ។

- តាមរយៈគ្រឹះស្ថាន TVET ក្រោមឱវាទក្រសួង ចំនួន ១០៧ ក្រោមឱវាទក្រសួងបានផ្តល់ការបណ្តុះបណ្តាលជំនាញដល់សិក្ខាកាម សិស្ស និស្សិត សរុបចំនួន ៥៣ ៧២៣នាក់ (ស្រី ១៩ ៩៤៩នាក់) ក្នុងនោះ កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១, ២, ៣ (C1,C2,C3) ចំនួន ១៦ ៧១៩នាក់ (ស្រី ៧ ៧៤២នាក់), សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ចំនួន ៥ ៦៦៦នាក់ (ស្រី ១ ២២៣នាក់) និងចាប់ពីបរិញ្ញាបត្របច្ចេកទេស/ឯកទេស/វិស្វករដល់បណ្ឌិត ចំនួន ៦ ៦០៣នាក់ (ស្រី ២ ០៣៧នាក់) លើមុខជំនាញសំខាន់ៗនៅក្នុងវិស័យអាទិភាព និងវគ្គក្រៅផ្លូវការចំនួន ២៤ ៧៣៥នាក់ (ស្រី ៨ ៩៤៧នាក់) ព្រមទាំងបានហ្វឹកហ្វឺនកូនជាង/ចុះកម្មសិក្សាចំនួន ៣៦ ១៥៥នាក់ (ស្រី ២៣ ២២១នាក់) និងបានធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុន (RPL) ចំនួន ១៣៩នាក់ (ស្រី ៧នាក់)។
- បានចុះបញ្ជីវិស្វករ ១ ១៨៣នាក់ (ស្រី ៤០នាក់) បើគិតត្រឹមឆ្នាំ២០២២ នេះ បានចុះបញ្ជីវិស្វករសរុបចំនួន ៧ ១៩១នាក់ (ស្រី ២៨០នាក់) ក្នុងនោះ វិស្វករជាតិ ចំនួន ៧ ០៨៨នាក់ (ស្រី ២៧៨នាក់) និងវិស្វករបរទេស ចំនួន ១០៣នាក់ (ស្រី ២នាក់)។
- បានពង្រឹង និងអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា TVET និងនៅតាមគ្រឹះស្ថាន TVET និងបានជំរុញឱ្យគ្រឹះស្ថាន TVET ទទួលបានវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO ចំនួន ៣បន្ថែម។
- បានខិតខំសិក្សាស្រាវជ្រាវនូវបច្ចេកវិទ្យាថ្មីៗ ទាក់ទងទៅនឹងផ្នែកអប់រំណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ការបង្កើតស្នាដៃ និងឧបករណ៍បច្ចេកទេសនានា ដើម្បីបម្រើការងារប្រចាំថ្ងៃ និងគាំទ្រដល់ឧស្សាហកម្ម។
- បានបន្តដំណើរការគ្រឹះស្ថាន TVET នៅក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធជាតិ TVET ពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform) និងគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានក្នុងបរិបទកូវីដ-១៩។

## ៣- ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស

- បានចុះបញ្ជីសហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធចំនួន ១៦ ៨២៨សហគ្រាស ដែលមានកម្មករនិយោជិតចំនួន ១,៥លាននាក់ ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមសរុបជាង ៣,៩៨ប៊ីលានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ។
- បានប្រមូលចុះឈ្មោះអ្នកស្វែងរកការងារចំនួន ១៨ ២៧៨នាក់ បានផ្គូផ្គងអ្នកស្វែងរកឱកាសការងារចំនួន ៣០ ៤៨០ ដង/នាក់ និងជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមមូលដ្ឋានភូមិឃុំ និងតាមរយៈវេទិកាការងារនានា ដែលរៀបចំដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់។
- បានផ្តល់សេវាប្រឹក្សាយោបល់អាជីពការងារ និងវិជ្ជាជីវៈ និងរៀបចំសិក្ខាសាលាណែនាំត្រៀមចូលការងារដល់អ្នកស្វែងរកការងារធ្វើ សិស្ស និស្សិតទាំងនៅតាមមជ្ឈមណ្ឌលការងារ និងតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា ចំនួន ១៦ ៥៤៤នាក់។
- បានផ្តល់សិក្ខាសាលាតម្រង់ទិស ដល់សិស្សានុសិស្សមធ្យមសិក្សាទុតិយភូមិស្តីពីការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សាផ្សារភ្ជាប់ទៅនឹងតម្រូវការទីផ្សារការងារ នៅតាមបណ្តាវិទ្យាល័យក្នុងរាជធានី ខេត្ត មានចំនួន ២៦៨វគ្គ មានអ្នកចូលរួម ចំនួន ១៣ ៥១០នាក់។

- បានផ្តល់សៀវភៅការងារ និងប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ សរុបចំនួន ៤១៣ ៥៥៦នាក់ (ស្រី ២៧៥ ៣៣៩នាក់) និងជនបរទេស ចំនួន ៩៥ ១៨២នាក់ (ស្រី ២២ ៨៥៧នាក់)។
- រហូតមកដល់បច្ចុប្បន្នបានផ្តល់ឱកាសការងារជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស សរុបមានចំនួន ១ ៣២១ ៥០៦នាក់ ក្នុងនោះ ប្រទេសថៃ មានចំនួន ១ ២៣១ ៥០៨នាក់ កូរ៉េ ៤៩ ៧៣៨នាក់, ជប៉ុន ១៦ ៥៦២នាក់, ម៉ាឡេស៊ី ២២ ៦២១នាក់, សឹង្ហបូរី ៨៥១នាក់, តំបន់រដ្ឋបាលពិសេសហុងកុង ២១៥នាក់ និងអារ៉ាប់ប៊ីសាអូឌីត ១១នាក់ ជាមធ្យមពលករបានបញ្ជូនប្រាក់បញ្ញើមកក្នុងប្រទេសវិញក្នុងមួយឆ្នាំៗសរុបប្រមាណ ២,៧ប៊ីលានដុល្លារអាម៉េរិក។
- បានបន្តជំរុញការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ សម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងការការពារ និងការលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍បងប្អូនពលករទាំងការទទួលបានកិច្ចគាំពារសង្គមក្នុងពេលបម្រើការងារ និងពេលត្រឡប់មកស្រុកកំណើតវិញ។

### ៤- ការអភិវឌ្ឍរបបសន្តិសុខសង្គម

- បានពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់កម្មករនិយោជិត ដោយបានចុះបញ្ជិការោងចក្រ សហគ្រាស សរុបចំនួន ២០ ១៧៥សហគ្រាស មានកម្មករនិយោជិតចំនួន ២ ៥៦៧ ៩៥៣នាក់ (ស្រី ១ ៦៣៨ ៦៦៩នាក់) និងបានផ្តល់តាវកាលិក ចំនួន ១៣ ២២៤ឯកសារ មានជនរងគ្រោះចំនួន ៨ ៦៧២នាក់ (ស្រី ៤ ៣៥៧នាក់)។
- បានចុះបញ្ជីផ្នែកហានិភ័យការងារសមាជិកជាមន្ត្រីសាធារណៈ មានចំនួន ៣៥ ក្រសួង ស្ថាប័ន មានសមាជិក ចំនួន ២៥៧ ១៣៤នាក់ (ស្រី ១០៧ ៣៣៧នាក់) និងបានផ្តល់តាវកាលិកចំនួន ៦៣ឯកសារ មានជនរងគ្រោះចំនួន ៦២នាក់ (ស្រី ១៥នាក់)។
- បានពង្រឹង និងពង្រីករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់កម្មករនិយោជិត ដោយការចុះបញ្ជិការោងចក្រ សហគ្រាស សរុបបាន ១៧ ៥៤៨សហគ្រាស មានកម្មករនិយោជិត ចំនួន ២ ៥៦៧ ៩៥៣នាក់ (ស្រី ១ ៦៣៨ ៦៦៩នាក់) និងបានផ្តល់ការពិនិត្យព្យាបាលជំងឺដោយមិនបង់ប្រាក់ចំនួន ២ ៥៣០ ៩៨៣ដង.នាក់ (ស្រី ១ ៩៤៣ ៣៨៨ដង.នាក់)។
- បានចុះបញ្ជីផ្នែកថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនបានចំនួន ៣៩ ក្រសួង ស្ថាប័ន មានសមាជិកសរុបចំនួន ៤៣៦ ៩៨៩នាក់ (ស្រី ១៣០ ៧៧៨នាក់) និងមានអ្នកទៅប្រើសេវាចំនួន ៣២២ ២៥៨ដង.នាក់។
- បានផ្តល់របបសន្តិសុខសង្គមដល់ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៩៤៧សហគ្រាស មានកម្មករសរុបចំនួន ៩៦ ១៩៨នាក់ (ស្រី ២០ ៨២៨នាក់)។
- បានពង្រីកវិសាលភាពចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី ខេត្ត ចំនួន ១ ៤៩៦ រួមមាន មន្ទីរពេទ្យថ្នាក់ជាតិ ចំនួន ៦, មន្ទីរពេទ្យបង្អែក ចំនួន ១២២, មណ្ឌលសុខភាពចំនួន ១ ២៤០ និងមន្ទីរពេទ្យឯកជន ចំនួន ១២៨ ដើម្បីឱ្យកម្មករទទួលបានសេវាដែលនៅជិតកន្លែងការងារ និងលំនៅដ្ឋាន។

- បានដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដោយបានចុះបញ្ជិកាពេលរោងចក្រ សហគ្រាស សរុបចំនួន ១៣ ៩៧៦ សហគ្រាស មានកម្មករនិយោជិត ចំនួន ១ ៤៣៤ ៤០៧នាក់។
- បានបន្តផ្តល់ប្រាក់ឧបត្ថម្ភស្ត្រីក្រោយពេលសម្រាលកូន ដែលមានស្ត្រីសម្រាលកូន សរុបចំនួន ៥៥ ៨០១នាក់ ស្មើនឹងចំនួនកូន ៥៦ ១៨៨នាក់ ដែលគិតជាទឹកប្រាក់អស់ប្រមាណ ២២,៤៨ប៊ីលាន រៀល (ប្រមាណ ៥,៤៨លានដុល្លារអាម៉េរិក)។
- បាននឹងកំពុងសិក្សាសមិទ្ធិលទ្ធភាព នៃការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនសម្រាប់សហគ្រិន បុគ្គលស្វ័យនិយោជន៍ និងកម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បាននឹងកំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធន ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធននិវត្តន៍។
- បានផ្សព្វផ្សាយអំពីសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់កម្មករនិយោជិតចំនួន ៣២ សហគ្រាស អ្នកចូលរួម សរុបចំនួន ២ ៣៤៤នាក់ ក្នុងនោះ កម្មករនិយោជិតចំនួន ១ ៨៣៧នាក់ និងអ្នកបើកបរចំនួន ៥០៧នាក់។

## ៥- ការពង្រឹងសេវាគាំទ្រទូទៅ

- បានបន្តចូលរួមអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ សំដៅកែលម្អគុណភាពសេវាសាធារណៈរបស់ក្រសួងឱ្យកាន់តែប្រសើរឡើង ព្រមទាំងបានពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមន្ត្រីរាជការឱ្យឆ្លើយតបនឹងសំណូមពរ និងតួនាទីភារកិច្ចរបស់ក្រសួង តាមរយៈកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព និងវិក្រឹត្យការមន្ត្រីគ្រប់ផ្នែក និងគ្រប់កម្រិត។
- បានបញ្ជូនមន្ត្រីទៅចូលរួមបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស សរុបចំនួន ៦ ២៩៧នាក់ ក្នុងនោះ បណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៦ ១២៩នាក់ ជាពិសេស បណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល ចំនួន ៥៨នាក់ និងបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ១៦៨នាក់។
- បានអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដោយយកចិត្តទុកដាក់អនុវត្តកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអនុវត្តតាមក្របខណ្ឌនៃកំណែទម្រង់ និងគោលនយោបាយពាក់ព័ន្ធ តាមរយៈយន្តការប្រមូលគ្រប់គ្រងចំណូល និងអនុវត្តចំណាយឱ្យកាន់តែមានស័ក្តិសិទ្ធភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពខ្ពស់ និងបានបន្តបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ទាន់ពេលវេលាកំណត់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។
- បានបន្តពង្រឹងកិច្ចសហការល្អជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងការអនុវត្តអនុសញ្ញាទាំង១៣ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងកាតព្វកិច្ចនានាក្នុងនាមកម្ពុជាជាសមាជិក។
- បានបន្តអនុវត្តលើគម្រោងជាមួយអង្គការអន្តរជាតិខាងការងារ រួមទាំង កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៧ (ILO-BFC) ដោយរាជរដ្ឋាភិបាលបានបន្ថែមបដិភាគថវិកាប្រហែល ១លានដុល្លារអាម៉េរិកក្នុងឆ្នាំ។

- បានបន្តអនុវត្តកម្មវិធីមុខរបរ និងការងារសមរម្យរបស់យុវជននៅកម្ពុជា (DEY) ដំណាក់កាលទី២ ឆ្នាំ២០២០-២០២៣ ដែលជាគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយប្រទេសចិន និងប្រទេសវៀតណាម។
- បានបន្តកិច្ចសហប្រត្តិបត្តិការជាមួយដៃគូជាច្រើនក្នុងការធ្វើឱ្យប្រសើរឡើងនូវវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា ADB, SDC, IOM, GIZ, JICA, KOICA, UNDP, UNESCO, UNIDO, UNICEF, UNFPA, UN Women, World Vision, CARE, APHEDA ។ល។
- បន្តផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីធានានិរន្តរភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានផ្តល់ថវិកាបន្ថែមប្រមាណ ១ ២០០លានរៀលក្នុងមួយឆ្នាំ។
- បានទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ាន ចំនួន ៩លើក លើប្រធានបទជាច្រើន ក្នុងនោះ ផ្តោតលើឧត្តមានុវត្តន៍ស្តីពីសុវត្ថិភាព និងសុខភាពការងារក្នុងសហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ទេសន្តរប្រវេសន៍ការងារ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអធិការកិច្ចការងារ។
- បានផ្តួចផ្តើម និងរៀបចំរហូតទទួលបានការអនុម័តពីប្រមុខរដ្ឋាភិបាលអាស៊ាននៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនូវសេចក្តីថ្លែងការណ៍អាស៊ានស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងអាស៊ាន។
- បានធ្វើជាម្ចាស់ផ្ទះនៃសន្និសីទនៃអង្គការសហព័ន្ធវិស្វកម្មអាស៊ានលើកទី៤០ ដោយសម្រេចបានសេចក្តីថ្លែងការណ៍ភ្នំពេញ ស្តីពីការផ្លាស់ប្តូរតួនាទីវិស្វករ ក្នុងយុគសម័យឧស្សាហកម្ម ៤.០។
- បានចូលរួមលើកកម្ពស់សមភាពយេនឌ័រ ដោយខិតខំអនុវត្តប្រកបដោយជោគជ័យស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១២ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងផែនការយុទ្ធសាស្ត្រនារីរតនៈ និងបានផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ (CEDAW) អនុសញ្ញាអង្គការអន្តរជាតិ។
- បានអនុវត្តអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង ១០ចំណុចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ប្រកបដោយជោគជ័យ ៖

១-គ្រប់រោងចក្រទាំងអស់ត្រូវអនុវត្តការបើកប្រាក់ឈ្នួល ២ដងក្នុងមួយខែ។

២-កម្មករនិយោជិតទទួលបានការពិនិត្យព្យាបាលជំងឺ ដោយមិនបង់ប្រាក់។

៣-កម្មការិនីទទួលបានប្រាក់ឈ្នួល ១២០% និងឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូនបានផ្តល់ប្រាក់ឈ្នួលដល់កម្មការិនីសម្រាលកូន។

៤-ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីក្រោយពេលសម្រាលកូន ដោយផ្តល់ជូនកូនចំនួន ១នាក់ ថវិកា ៤០ម៉ឺនរៀល, កូនចំនួន ២នាក់ ថវិកា ៨០ម៉ឺនរៀល និងកូនចំនួន ៣នាក់ ថវិកា ១,២លានរៀល ព្រមទាំងទទួលបានថវិកាបន្ថែមចំនួន ៥លានរៀល ពី សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ផ្ទាល់។

៥-និយោជកបានបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករនិយោជិត។

៦-ស្ថាប័នពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តត្រួតពិនិត្យថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនីនៅតាមផ្ទះជួល និងជំរុញការតភ្ជាប់បណ្តាញអគ្គិសនី និងទឹកស្អាតនៅតាមតំបន់ផ្ទះជួលរបស់កម្មករនិយោជិត។

៧-ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ទទួលបានការអនុម័ត និងដាក់ឱ្យប្រើប្រាស់ដើម្បីអនុវត្តផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត និងផ្នែករបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ។

៨-អនុវត្តច្បាប់ស្តីពីការងារ ដើម្បីកំណត់ការបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត ៦ខែម្តង។

៩-បានសហការជាមួយក្រសួងពាក់ព័ន្ធ បន្តដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ការរៀបចំកែសម្រួលមធ្យោបាយដឹកជញ្ជូន និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក។

១០-បានពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ និងផលប្រយោជន៍ពលករ ដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

## II- ទិសដៅអនុវត្តបន្តឆ្នាំ២០២៣

១-បន្តអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង ១០ ចំណុចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

២-បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដើម្បីធានាការការពារសិទ្ធិ សេរីភាពអង្គការវិជ្ជាជីវៈ សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចគាំពារសង្គម។

៣-ពង្រឹងយន្តការអធិការកិច្ចការងារតាមប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា និងពង្រឹងប្រសិទ្ធភាពការងាររបស់ក្រុមអធិការកិច្ចអន្តរស្ថាប័ន សំដៅធានាបាននូវវប្បធម៌អនុលោមភាពនៅតាមសហគ្រាស។

៤-បន្តលើកទឹកចិត្តឱ្យរោងចក្រ សហគ្រាសមួយ ជាសហគមន៍សុខសាន្តមួយ មានសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ មានលក្ខខណ្ឌការងារល្អប្រសើរ មានការទទួលខុសត្រូវសង្គម និងកម្មករនិយោជិតមានផលិតភាពការងារខ្ពស់ និងមានឥរិយាបថការងារល្អ។

៥-បន្តការយកចិត្តទុកដាក់លើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់សហគ្រិន និងកម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីទទួលបាននូវការការពារសិទ្ធិ ជំនាញវិជ្ជាជីវៈ និងកិច្ចគាំពារសង្គម។

៦-បន្តពង្រឹងទំនាក់ទំនងជាមួយបណ្តាប្រទេសនានា ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ សង្គមស៊ីវិល និងអង្គការវិជ្ជាជីវៈ ទាំងកម្រិតទ្វេភាគី ពហុភាគី ក្នុងក្របខណ្ឌតំបន់ និងពិភពលោក ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៧-បន្តពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥, គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ និងគោលនយោបាយស្តីពីពលករទេសន្តប្រវេសន៍ ឆ្នាំ២០១៩-២០២៣។

៨-បន្តពង្រឹងអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអនុវត្តផែនការមេសម្រាប់អភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០២១-២០២៥ សំដៅកសាងសមត្ថភាពស្ថាប័នអភិវឌ្ឍសមត្ថភាពមន្ត្រី និងគ្រូបច្ចេកទេស សមត្ថភាព គ្រប់គ្រង និងភាពជាអ្នកដឹកនាំ និងការពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា រួមទាំងយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តការងារ។

៩-បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមគាំទ្រដល់ការបង្កើនសមត្ថភាពជំនាញ (Upskilling) និងបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) នៃកម្លាំងពលកម្មដែលកំពុងស្ថិតនៅក្នុងទីផ្សារការងារស្រាប់ និងឱកាសការងារថ្មីៗ។

១០-ពង្រីកការបណ្តុះបណ្តាលជំនាញកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) ជាពិសេសដល់សមាជិកគ្រួសារក្រីក្រ (ក្រ១ និងក្រ២) ចំនួន ១,៥លាននាក់ ដោយរាជរដ្ឋាភិបាលផ្តល់ជូននូវប្រាក់ឧបត្ថម្ភក្នុងពេលសិក្សា ដើម្បីទទួលបានឱកាសការងារធ្វើ និងបង្កើតមុខរបរដោយខ្លួនឯង។

១១-ពង្រឹង និងពង្រីកវិសាលភាពក្នុងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ ព្រមទាំងការផ្តល់ប្រឹក្សាយោបល់ការងារអាជីព ដើម្បីធ្វើការផ្គូផ្គង និងឆ្លើយតបបាននូវតម្រូវការកម្លាំងពលកម្មតាមទីផ្សារការងារ ដោយបង្កើនភាពជាដៃគូជាមួយវិស័យឯកជន។

១២-បន្តបង្កើនវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិការងារ ដើម្បីបង្កើនសមត្ថភាពមន្ត្រីអធិការការងារ អធិការពេទ្យការងារ អភិបាលការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារ និងផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូសង្គម អង្គការវិជ្ជាជីវៈ សិស្ស និស្សិត និងភាគីពាក់ព័ន្ធឱ្យយល់ដឹងពីច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ។

១៣-បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ គោលនយោបាយជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីស្របតាមការវិវត្តនៃសេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣